ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ: ១៥៧៥/១៩ ក.អ.ជ

ថ្ងៃសុក្រ ១៥កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៩

# របាយការណ៍

## វឌ្ឍនភាពការងារប្រចាំខែសីហា ឆ្នាំ ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

### I. សេចក្តីផ្តើម

ក្នុងខែសីហា ឆ្នាំ២០១៩ ព្រះរាជាណាចក្រកម្ពុជាមានភ្លៀងធ្លាក់ច្រើនដោយឥទ្ធិពលព្យុះមកពីប្រទេសចិន និងចំពេលរដូវវស្សាផងនោះ បានបង្កឲ្យទឹកទន្លេមេគង្គហក់ឡើងយ៉ាងខ្លាំងរហូតដល់កម្រិតប្រកាសអាសន្ននៅចុងខែសីហានេះ ធ្វើឲ្យទឹកជនលិចភូមិករ ផ្ទះសម្បែងអ្នកស្រុកព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជាផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព អណ្តូងទឹក ស្រះទឹក បង្គន់អនាម័យ ។ល។ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើថ្នាក់ដឹកនាំក្រសួងគ្រប់លំដាប់ថ្នាក់រហូតដល់មន្ទីរអភិវឌ្ឍន៍ជនបទបានចុះតាមដាន និងជួយសង្គ្រោះប្រជាពលរដ្ឋនៅតាមបណ្តាខេត្តដែលមានទឹកជំនន់ដោយបានជួយជន្លៀសប្រជាជនទៅរកទីទួលសុវត្ថិភាព និងបានផ្តល់សម្ភារៈប្រើប្រាស់មួយចំនួនដល់ជនរងគ្រោះផងដែរ ។

ចំពោះការងារជំនាញ ក្រសួងបានបន្តអនុវត្តផែនការប្រចាំឆ្នាំបន្តទៀតដើម្បីគាំទ្រដល់ការអភិវឌ្ឍជនបទនៅទូទាំងប្រទេស ។ លទ្ធផលសម្រេចបានក្នុងខែសីហា ឆ្នាំ២០១៩ នេះមានដូចខាងក្រោម៖

### II. អំពីការងារគ្រប់គ្រងរបស់ក្រសួង

១. ការងាររដ្ឋបាល និងបុគ្គលិក

ដោយគិតត្រឹមដំណាច់ខែសីហា ឆ្នាំ២០១៩ មន្ត្រីរាជការក្របខណ្ឌសរុបមានចំនួន ១ ៨០១ នាក់ ប្រៀបធៀបនឹងចំនួនមន្ត្រីរាជការកាលពីដំណាច់ខែកក្កដា ឆ្នាំ២០១៩ គឺមានការកើនឡើងចំនួន ០២នាក់ ដោយការផ្ទេរក្របខណ្ឌចូល ។ ក្រសួងបានទទួលលិខិតចូលចំនួន ១៧២ច្បាប់ លិខិតចេញក្រៅក្រសួងចំនួន ១២៧ច្បាប់ ចុះលេខប្រកាស និងសេចក្តីសម្រេចនានាចំនួន ០២១ច្បាប់ និងចុះលេខលិខិតបេសកកម្មចំនួន ២១៣ច្បាប់ ។

២. ក្រុមការងារចុះមូលដ្ឋានតាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤

ក្នុងខែសីហា ឆ្នាំ២០១៩ លេខាធិការដ្ឋានទទួលបានសំណើ សំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានតាមរយៈវេទិកាសាធារណៈថ្នាក់ជាតិ សរុបចំនួន ២៦ ករណី ដែលក្នុងនោះបានដោះស្រាយជូនប្រជាពលរដ្ឋបានចំនួន ១១ ករណី ។

៣. ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

ក្នុងខែសីហា នេះ ក្រសួងបានអនុវត្តចំណាយធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៩

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល dap.mrd@gmail.com

សម្រេចបាន ៖

- ចំណាយចរន្តអនុវត្តបានចំនួន ៨ ៥០៦ ០៧២ ៨៣០ រៀល ស្មើនឹង ៦,៤៩% នៃច្បាប់ថវិកា
- ចំណាយមូលធនអនុវត្តបានចំនួន ២២ ៤២៥ ៨៩៩ ៣២៨ រៀល ស្មើនឹង ១១,៨០% នៃច្បាប់ថវិកា ។

**៤. ការងារផែនការ និងសហប្រតិបត្តិការអន្តរជាតិ**

- ចូលរួមពិធីសំណេះសំណាលជាមួយស្ថានឯកអគ្គរដ្ឋទូតថ្មីប្រទេសម៉ាឡេស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។ ដោយក្នុងនោះ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី បានបង្ហាញផែនការអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៩-២០២៣ ដែលមានកម្មវិធីចំនួន ៤ ដើម្បីជំរុញលើកស្ទួយសុខមាលភាព និងបង្កើនជីវភាពរស់នៅរបស់ប្រជាជននៅជនបទដើម្បីកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់ប្រជាជនជនបទឲ្យបានល្អប្រសើរឡើងថែមទៀត
- រៀបចំកិច្ចប្រជុំប្រចាំខែសីហា របស់នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈដឹកនាំដោយ **ឯកឧត្តមបណ្ឌិត សៅ ជីវ័ន្ត** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមប្រជុំពិគ្រោះយោបល់អន្តរជាតិលើគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ានលើកទី៣ ( National Consultation ASEAN IAI Workplan III ) នៅសណ្ឋាគាសាន់វេ ភ្នំពេញ
- បញ្ចប់ការរៀបចំរបាយការណ៍សូចនាករសម្រាប់តាមដានការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល លើវិស័យអភិវឌ្ឍន៍ជនបទ
- ចូលរួមចរចារផែនការថវិកាប្រចាំ ឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទកម្រិតគោលនយោបាយ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមសិក្ខាសាលារៀបចំផែនការស្តីពី Promotions on Rural Development and Poverty Eradication among LMC Countries through Exchanges នៅទីក្រុង Nay Pyi Taw ប្រទេសភូមា
- ចុះត្រួតពិនិត្យការធ្វើអង្កេតទិន្នន័យអភិវឌ្ឍន៍ជនបទ និងពង្រឹងស្ថិតិ នៅខេត្តកំពង់ធំ និងកំពង់ចាម
- ចុះពិនិត្យការអនុវត្តផែនការឆ្នាំ ២០១៩ និងពិនិត្យកែសម្រួលផែនការកម្មវិធីឆ្នាំ ២០២០ របស់មន្ទីរអភិវឌ្ឍន៍ជនបទ នៅខេត្តក្រចេះ ព្រៃវែង និងស្វាយរៀង
- ចូលរួមសិក្ខាសាលាស្តីពីការរៀបចំប្រព័ន្ធតាមដាន និងវាយតម្លៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំនួន ០២លើក
- រៀបចំ និងបញ្ជូនរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) ដែលបានសម្រេចបានក្នុងឆ្នាំ២០១៧ និង២០១៨ លើវិស័យអភិវឌ្ឍន៍ជនបទកន្លងមកទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ចូលរួមកិច្ចប្រជុំបច្ចេកទេស (Pre wrap up meeting) ដើម្បីពិភាក្សាការងារអំពីលទ្ធផលបឋម នៃការវាយតម្លៃលើការគ្រប់គ្រងការវិនិយោគសាធារណៈ ជាមួយក្រុមបេសកកម្មមូល

និធិរូបិយវត្ថុអន្តរជាតិ (IMF) នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាលក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ២០២០- ២០២២ នៅទីស្តីការគណៈរដ្ឋមន្ត្រី
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យផ្លូវជនបទ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងគេហទំព័រក្រសួងអភិវឌ្ឍន៍ជនបទ
- បានផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-អូស្ត្រាលី ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ចុះពិនិត្យការងាររបស់អង្គការក្រៅរដ្ឋាភិបាលនៅខេត្តឧត្តរមានជ័យ និងកោះកុង ។

៥. ការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ជួបប្រជុំជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកំណែទម្រង់ដំណាក់កាលទី៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដឹកនាំដោយ **ឯកឧត្តម ហ្វួត សារឹម** អនុរដ្ឋលេខាធិការ និងជាអនុប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសារណៈក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមប្រជុំត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាសទី២ របស់ក្រសួងដឹកនាំដោយ **ឯកឧត្តម ហ្វួត សារឹម** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចុះតាមដាន ត្រួតពិនិត្យការអនុវត្តថវិកាកម្មវិធីនៅតាមអង្គភាពមន្ទីរអភិវឌ្ឍន៍ជនបទខេត្តចំនួន ០៤ គឺ ស្វាយរៀង ព្រៃវែង កំពង់ចាម ក្រចេះ ។ លទ្ធផលអនុវត្តទាន់ផែនការប្រចាំឆ្នាំបានល្អប្រសើរ ។
- បន្តកែសម្រួលរៀបចំផែនការថវិកាកម្មវិធីឆ្នាំ២០២០ បន្ទាប់ពីការចរចារថវិកាលើកទី២
- ឆ្លើយតបនឹងក្រុមការងារវាយតម្លៃ IMF on Public Investment management Assessment (PIMA) ។

៦. ការងារអធិការកិច្ច និងសវនកម្ម

- ចុះធ្វើអធិការកិច្ចលើការងារគ្រប់គ្រងចំណូល-ចំណាយ និងការប្រើប្រាស់ថវិការបស់រដ្ឋការិយបរិច្ឆេទ ២០១៨ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ចំនួន ០២ ក្នុងនោះរួមមាន៖ ខេត្តសៀមរាប និងបន្ទាយមានជ័យ
- ចុះធ្វើសវនកម្មលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ថវិកាតាមកម្មវិធី ឆ្នាំ ២០១៨ - ២០១៩ និងចុះពិនិត្យជាក់ស្តែងការងារសាងសង់ ជួសជុលអណ្តូងទឹក និងសាងសង់បង្គន់អនាម័យដោយប្រើប្រាស់ថវិការដ្ឋនៅមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី ខេត្តចំនួន ០៣ រួមមាន រាជធានីភ្នំពេញ ខេត្តព្រះវិហារ និងខេត្តកំពង់ធំ
- ចូលរួមកិច្ចប្រជុំស្តីពី ការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋថវិកាបើកផ្តល់ពីក្រសួងសាមី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងទ្រព្យ

សម្បត្តិរដ្ឋ និងកាតព្វកិច្ចត្រូវបង់ចំណូលចូលថវិការដ្ឋក្នុងការិយបរិច្ឆេទ ២០១៨ និងបណ្ដាឆ្នាំពាក់ព័ន្ធ ក្រោមអធិបតីភាព **ឯកឧត្តម ម៉ុន ច័ន្ទវណ្ណៈ** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ

- បានចូលរួមវេទិកាស្តីពី មុខងារនីតិកម្ម និងការងារកែតម្រង់របស់រដ្ឋាភិបាល ក្រោមអធិបតីភាព **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅទីស្តីការក្រសួងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានចុះប្រមូលពត៌មាន និងស្រាវជ្រាវពីករណីការបង្ហោះព័ត៌មាន អំពីអំពើពុករលួយរបស់ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ នៅលើគេហទំព័រផែនដីថ្មី ។

## III. សកម្មភាពការងារជំនាញ

### ១. ការងារអភិវឌ្ឍន៍ផ្លូវជនបទ

- គម្រោងស្ថាបនា កែលម្អផ្លូវ និងសំណង់សិល្បការ្យ ឆ្នាំ២០១៩ មាន ៩៦ គម្រោង កំពុងដំណើរការការដ្ឋានបានចំនួន ៧៧ គម្រោង លទ្ធផលគិតជាមធ្យម ៥១.៣៧ %
- ការងារថែទាំផ្លូវលក្ខណៈខួប ឆ្នាំ២០១៩ មាន ចំនួន ២៨ គម្រោង ស្មើនឹង ៦៣ ខ្សែ ដំណើរការការដ្ឋានលទ្ធផលគិតជាមធ្យម ៧៩.៨៩ %
- ការងារថែទាំផ្លូវលក្ខណៈប្រចាំ ឆ្នាំ២០១៩ មានចំនួន ៤០ គម្រោង ស្មើនឹង ៣៦៩ ខ្សែ ដំណើរការការដ្ឋានលទ្ធផលគិតជាមធ្យម ៧២.២៧ %
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចុះត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់សុពលភាព ១៧ គម្រោង អនុវត្តដោយ នាយកដ្ឋានស្ថាបនា និងវិស្វកម្ម នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ កងវិស្វកម្មសម្តេចតេជោខេត្តសៀមរាប និងនាយកដ្ឋានផ្លូវលំជនបទ លើការងារស្ថាបនា
- ចូលរួមជាមួយគណៈកម្មការអន្តរក្រសួងចរចាថ្លៃបានចំនួន ១២គម្រោង អនុវត្តដោយនាយកដ្ឋានស្ថាបនា និងវិស្វកម្មនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ កងវិស្វកម្មសម្តេចតេជោខេត្តសៀមរាប និងនាយកដ្ឋានផ្លូវលំជនបទ លើការងារស្ថាបនា
- ចូលរួមសិក្ខាសាលា ស្តីពីបច្ចេកទេសការជួសជុលផ្លូវថ្នល់ដោយប្រើវិធីសាស្ត្រ Cold in Place Recycling នៅទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន
- ចូលរួមប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន INTERNATIONAL PROTECTIVE SECURITY AGENT CO.LTD លើបច្ចេកទេសសាងសង់ផ្លូវដោយប្រើបច្ចេកវិទ្យា AGGREBING នៅទីស្តីការក្រសួងអភិវឌ្ឍន៍ផ្លូវជនបទ ។

### ២. ការងារផ្គត់ផ្គង់ទឹកជនបទ

- ចូលរួមកិច្ចប្រជុំចរចាថ្លៃលើគម្រោងការងារសាងសង់ អណ្តូង អាងត្រងទឹកភ្លៀង ប្រព័ន្ធចែកចាយទឹកខ្នាតតូច ស្តាប្រឡាយ និងស្តាស្រះសហគមន៍ចំនួន ០៧ គម្រោង នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចុះត្រួតពិនិត្យ និងវាយតម្លៃគ្រឿងចក្រខួងអណ្តូងឯកជន នៅខេត្តកំពង់ធំ តាកែវ កំពង់ចាម

សៀមរាប ឧត្តរមានជ័យ ក្រចេះ ត្បូងឃ្មុំ និងរតនគិរី
- ចុះត្រួតពិនិត្យ និងវាយតម្លៃសំណង់ ស្រះសហគមន៍ និងអណ្តូងស្នប់អាហ្វ្រីដេវ នៅខេត្តកែប ព្រះសីហនុ កោះកុង និងកណ្តាល
- ចុះសិក្សាទីតាំងសាងសង់អណ្តូងស្នប់អាហ្វ្រីដេវ អណ្តូងទឹក និងស្ថានីយ៍ទឹកសហគមន៍ នៅខេត្តកែប ខេត្តព្រះសីហនុ កោះកុង និងកណ្តាល
- ចូលរួមចរចាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដំហានទី ៣ នៅស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីទឹកស្អាត និងអនាម័យ ក្រោមប្រធានបទ " មិនទុកចោលនរណាម្នាក់៖ សេវាទឹកស្អាត និងអនាម័យប្រកបដោយចីរភាពក្នុងបរិបទនៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស " នៅសាលាសម្រាប់បណ្តុះបណ្តាលអំពីទឹកសិង្ហបុរី (PUB) ប្រទេសសិង្ហបុរី
- ចូលរួមជាវាគ្មិនកិត្តិយសសម្ភាសន៍ជាមួយវិទ្យុជាតិកម្ពុជា ក្រោមប្រធានបទ "ស្វែងរកដំណោះស្រាយទឹកស្អាតសម្រាប់ប្រជាពលរដ្ឋរស់ នៅក្នុងភូមិបណ្តែតទឹក លើបឹងទន្លេសាប"
- ចូលរួមធ្វើជាវាគ្មិនកិត្តិយស ក្នុងកម្មវិធីតុមូល ក្រោមប្រធានបទ យន្តការក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត នៅមូលដ្ឋាន នៅស្ថានីយ៍វិទ្យុបាយ័ន រាជធានីភ្នំពេញ
- ចូលរួមប្រជុំត្រួតពិនិត្យគោលការណ៍ណែនាំជាតិ ស្តីពីគុណភាពទឹកផឹកជនបទ និងផែនការសកម្មភាពជាតិ ស្តីពីគុណភាពទឹកជនបទ ។

**៣. ការងារថែទាំសុខភាព និងអនាម័យជនបទ**

- សាងសង់បង្គន់ អនាម័យឯកជនចាក់ទឹក បានចំនួន ៣២ បង្គន់ នៅខេត្តបន្ទាយមានជ័យ
- ផ្តល់ចានបង្គន់តាមផ្ទះឯកជន បានចំនួន ៦៤ ចានបង្គន់ នៅខេត្តកែប
- សហការជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង ក្នុងការការរៀបចំពិធីប្រារព្ធប្រកាសស្រុករំដួល ជាស្រុកបានបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (ODF) ក្រោមអធិបតីភាព **ឯកឧត្តម ទ្រី មេង** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានអ្នកចូលរួមប្រមាណជាង ១ ០០០ នាក់
- សហការជាមួយអង្គការ SNV ក្នុងគម្រោង Nourish ដឹកនាំការពិនិត្យផ្ទៀងផ្ទាត់ភូមិ ODF ចំនួន០៤ភូមិ ក្នុងស្រុកកណ្តៀង និងស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់ ជាលទ្ធផលភូមិទាំង ០៤ បានជាប់ជាភូមិ ODF
- ចុះជំរុញការសាងសង់ និងប្រើប្រាស់បង្គន់អនាម័យនៅតាមសហគមន៍នៅខេត្តក្រចេះ កំពង់ឆ្នាំង កំពង់ស្ពឺ ស្វាយរៀង កោះកុង ព្រះសីហនុ ប៉ៃលិន កំពង់ចាម ឧត្តរមានជ័យ សៀមរាប កែប និងត្បូងឃ្មុំ
- ចុះធ្វើការវាយតម្លៃ និងផ្សព្វផ្សាយគោលការណ៍ណែនាំកម្មវិធីទឹកស្អាត និងអនាម័យតាមសាលារៀន និងសហគមន៍នៅខេត្តប៉ៃលិន និងស្វាយរៀង ដែលមានអ្នកចូលរួមសរុប ១០៣នាក់ ស្រី៣៦នាក់
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីអំពីការចូលរួមរបស់ប្រទេសកម្ពុជាក្នុង

ការអនុវត្តកម្មវិធីលើកកម្ពស់ទឹកស្អាត និងអនាម័យឆ្នាំ ២០១៩-២០២០ នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ

- ដឹកនាំកិច្ចប្រជុំក្រុមការងារបច្ចេកទេសអនាម័យ ក្នុងតំបន់ប្រឈមនឹងបរិស្ថាន (SCE technical team meeting) ដើម្បីពិភាក្សាការងារជាមួយដៃគូអង្គការនានាអំពីតួនាទី និងការទទួលខុសត្រូវព្រមទាំងការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការអនុវត្តអនាម័យក្នុងតំបន់ប្រឈមនឹងបរិស្ថាន នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំស្តីពីចលនាបង្កើនអាហារូបត្ថម្ភនៅកម្ពុជា ក្រោមអធិបតីភាព **ឯកឧត្តម យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៅទីស្តីការគណៈរដ្ឋមន្ត្រី
- ចូលរួមសិក្ខាសាលាចែករំលែកបទពិសោធន៍នៃការគ្រប់គ្រង និងផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល នៅវិទ្យាស្ថានជាតិអប់រំ ក្រោមអធិបតីភាព **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ។

៤. ការងារអភិវឌ្ឍន៍សហគមន៍

- ចុះពិនិត្យវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅខេត្តកំពង់ចាម បន្ទាយមានជ័យ កំពង់ស្ពឺ ឧត្តរមានជ័យ កំពង់ធំ កំពង់ឆ្នាំង ត្បូងឃ្មុំ ស្វាយរៀង ព្រៃវែង តាកែវ បាត់ដំបង និងរតនគិរី
- ចុះពិនិត្យវគ្គបណ្តុះបណ្តាល ស្តីពី សួនដំណាំគ្រួសារ និងរបៀបធ្វើជីកំប៉ុស នៅខេត្តកែប និងសៀមរាប
- ចុះពិនិត្យវគ្គបណ្តុះបណ្តាល ស្តីពី ការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យក្នុងសហគមន៍ នៅខេត្តបន្ទាយមានជ័យ និងសៀមរាប
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានធ្វើការផ្សព្វផ្សាយវបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទាំងនៅក្នុងមជ្ឈមណ្ឌល និងក្រៅមជ្ឈមណ្ឌល ចំនួន២៣វគ្គ មានសិក្ខាកាមចំនួន ៣៨០នាក់ ។

៥. ការងារបណ្តុះបណ្តាល

- មន្ត្រីចូលរួមសិក្ខាសាលាក្នុងប្រទេស ចំនួន ២៤៥នាក់ ក្នុងនោះស្រីចំនួន ៣៥នាក់
- មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន ១០០នាក់ ក្នុងនោះស្រីចំនួន ១៥នាក់
- បានរៀបចំសិក្ខាសាលា ចំនួន០២វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១៦២នាក់ ស្ត្រី ២៤នាក់
- បានរៀបចំឯកសារចាត់បញ្ជូនមន្ត្រី ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល ចូលរួមសិក្ខាសាលា និងចូលរួមការប្រកួតប្រជែងវគ្គបណ្តុះបណ្តាលកម្មវិធីភាសាអង់គ្លេស ក្នុងប្រទេស និងក្រៅប្រទេស ជូនមន្ត្រី ចំនួន ១៤នាក់
- ផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការជ្រើសរើសជំនាញការតាមដានត្រួតពិនិត្យអាកាសធាតុ និងទឹក (Water and Climate Monitoring Specialist) ដើម្បីបម្រើការងារនៅលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គ (MRCS) នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ

- បានរៀបចំឯកសារសំណើសុំគាំទ្រ និងសម្របសម្រួលដើម្បីចុះធ្វើកម្មសិក្សាស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនមន្ត្រីនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ ទៅសាលាខេត្តកំពង់ចាម
- បានរៀបចំឯកសារចាត់មន្ត្រីចំនួន ១០រូប ដែលជាអតីតកម្មសិក្សាការីដែលធ្លាប់ទទួលបានការបណ្តុះបណ្តាលវគ្គវែង ខ្លី នៅសាធារណរដ្ឋកូរ៉េ ដើម្បីចូលរួមសកម្មភាពជួយសង្គម នៅខេត្តព្រៃវែង
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង បានបញ្ចប់វគ្គបណ្តុះបណ្តាលឆមាសទី១ និងចុះធ្វើការផ្សព្វផ្សាយនៅតាមតំបន់គោលដៅចំនួន ០៣ស្រុក ព្រមទាំងបានធ្វើការផ្សព្វផ្សាយជ្រើសរើសសិក្ខាកាម សម្រាប់ឆមាសទី២ ឆ្នាំ២០១៩
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ បានបើកវគ្គបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី សម្រាប់ឆមាសទី២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១៩៤នាក់ ស្រី ៧៣នាក់ លើ ០៦មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបន្តដំណើរការបណ្តុះបណ្តាល សម្រាប់ឆមាសទី១ និងបើកវគ្គទី ២ បន្ថែមសម្រាប់ឆមាសទី២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ២១៧នាក់ ស្រី ១៦០នាក់ លើ ០៥មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង បានចុះធ្វើការផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមសម្រាប់ឆមាសទី២ ឆ្នាំ២០១៩ នៅតាមតំបន់គោលដៅនៅក្នុង ស្រុកសង្កែ និងបានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លីចំនួន ០១ វគ្គ លើមុខជំនាញថែទាំគ្រឿងយន្តកសិកម្ម ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ២០នាក់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់ បានបើកវគ្គបណ្តុះបណ្តាល សម្រាប់ឆមាសទី២ និងបើកវគ្គរយៈពេលខ្លី ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ១១៥នាក់ ស្រី ៦៩នាក់លើ ០៤មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពត បានបន្តដំណើរការបណ្តុះបណ្តាលរយៈពេលវែង និងបានបើកវគ្គរយៈពេលខ្លី សម្រាប់ឆមាសទី១ និងសម្រាប់ឆមាសទី២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៧៩នាក់ ស្រី ៣៧នាក់ លើ ០៣មុខជំនាញ
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ បានរៀបចំសម្ភារៈសម្រាប់ត្រៀមបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លីលើមុខវិជ្ជាបច្ចេកទេសចិញ្ចឹម និងព្យាបាលមាន់
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ បានបន្តដំណើរការបណ្តុះបណ្តាលសម្រាប់ឆមាសទី១ និងសម្រាប់ឆមាសទី២ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន ៤១នាក់ ស្រី ១៨នាក់ លើមុខវិជ្ជាភាសាអង់គ្លេស
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តសៀមរាប បន្តរៀបចំផែនការ និងស្រង់ទិន្នន័យអ្នកមានបំណងចូលរៀនព្រមទាំងបន្តការផ្សព្វផ្សាយពីគម្រោងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនាពេលខាងមុខ ។

៦. ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

- គិតត្រឹមថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ប្រតិបត្តិករឥណទានជនបទដែលមន្ទីរអភិវឌ្ឍន៍ជនបទខេត្តអនុវត្តផ្ទាល់ និងសហការជាមួយដៃគូ និងសកម្មភាពការងារឥណទានដែលអនុវត្តដោយសហគមន៍សន្សំប្រាក់ បានផ្តល់ឥណទានសរុបចំនួន ៤ ១៥០ ១៥៤ ៤៣៥ រៀល (បួនពាន់មួយរយហាសិបលានមួយរយហាសិបបួនពាន់បួនរយសាមសិបប្រាំរៀល) ស្មើនឹង ១ ០៥៦ ៧៦៤,៥៧ ដុល្លារ អាមេរិក (មួយលានហាសិបប្រាំមួយពាន់ប្រាំពីររយហុកសិបបួនដុល្លារនិងហាសិបប្រាំពីរសេន) (១USD=៤០០០រៀល) មានអ្នកខ្ចីសរុបចំនួន ៤ ៣៩១នាក់ នៅភូមិគោលដៅចំនួន ២២៦ភូមិ ១០០ឃុំ ៣២ស្រុក ក្នុងខេត្តគោលដៅចំនួន ១៥
- ធ្វើការបូកសរុប និងសម្របសម្រួលគាំទ្រផ្នែក បច្ចេកទេសគ្រប់គ្រងធនាគារស្រូវដល់សហគមន៍ដែលមានស្រូវសរុបចំនួន ១០ ០០០ គ.ក ស្ថិតនៅដៃសមាជិកកំពុងប្រើប្រាស់សរុបចំនួន ៨៦នាក់ ស្រី ៦៤នាក់ នៅខេត្តស្វាយរៀង
- ចុះតាមដានសកម្មភាពសិក្ខាកាមក្រោយវគ្គបណ្តុះបណ្តាលគំនិតផ្តួចផ្តើមបង្កើតអាជីវកម្មខ្នាតតូច និងបច្ចេកទេសផលិតសាប៊ូលាងចាន នៅខេត្តរតនគិរី និងសៀមរាប
- ចុះផ្សព្វផ្សាយ និងទំនាក់ទំនងជាមួយ អាជីវករ ផលិតករ ឲ្យចូលរួមតាំងពិព័រណ៌ពាណិជ្ជកម្មដែលគ្រោងធ្វើនៅទីរួមខេត្តកំពង់ធំ
- ចូលរួមប្រជុំ និងផ្សព្វផ្សាយការអនុវត្តគម្រោងមេគង្គ-ឡានឆាង របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី" Advanced Course on Trade in Services under the WTO and FTAs " នៅមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី ។

៧. ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ជនជាតិដើមភាគតិច

- ដឹកនាំកិច្ចប្រជុំ ស្តីពី ការរៀបចំទិវា អន្តរជាតិជនជាតិដើមភាគតិចលើកទី២៥ ជាមួយមន្ត្រីពាក់ព័ន្ធ និងអង្គការ ដៃគូ ចំនួន ០២លើក នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមពិធីប្រគល់លិខិតទទួលស្គាល់អត្តសញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិចគ្រឹង នៅស្រុកអូរជុំ ខេត្តរតនគិរី
- ទំនាក់ទំនងជាមួយអង្គការដៃគូ និងក្រសួងពាក់ព័ន្ធ ដើម្បីរៀបចំធ្វើផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិចតាមបណ្តាខេត្តទាំង ១៥ ។

៨. ការងារយេនឌ័រ

- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី៥០ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដើម្បីពិនិត្យផ្តល់ធាតុចូលបន្ថែម និងសម្រេចលើសេចក្តីព្រាងរបាយការណ៍ឆ្លើតបទៅនឹងបញ្ជីបញ្ហា និងសំណួរពាក់ព័ន្ធទៅនឹងរបាយការណ៍ជាតិតាមការកំណត់លើកទី៦ របស់កម្ពុជា (List of issues and question) នៃការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនារីភេទ ដែលផ្តល់ដោយគណៈកម្មាធិការ CEDA នៃអង្គការសហប្រជាជាតិ នៅភោជនីយដ្ឋានទន្លេបាសាក់២

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារការប៉ាន់ប្រមាណ យេនឌ័រនៅកម្ពុជា (២០១៩-២០២៣) នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងទី២ នៃផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហឹង្សាលើស្ត្រីលើកទី៣ ឆ្នាំ២០១៩-២០២៣ នៅសណ្ឋាគារសាន់វ៉េ ។

៩. ការងារប្រយុទ្ធនឹងជំងឺអេដស៍

- រៀបចំប្រជុំក្រុមការងារដើម្បីរៀបចំផែនការសម្រាប់អនុវត្តការងារ ឆ្នាំ២០១៩ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

១០. ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ

- រៀបចំផ្ទេរមុខងារក្នុងវិស័យអភិវឌ្ឍន៍ជនបទចំនួន ០៣ ដោយប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងព្រះរាជាណាចក្រកម្ពុជាចាប់ពី ឆ្នាំ២០២០ តទៅ
- រៀបចំកិច្ចប្រជុំដំបូងរបស់ក្រុមលេខាធិការដ្ឋានវិមជ្ឈការ និងវិសហមជ្ឈការក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីរៀបចំផែនការបណ្តុះបណ្តាលមុខងារថែទាំផ្លូវជនបទជាលក្ខណៈប្រចាំ និងជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ
- ប្រជុំពិភាក្សាជាមួយនាយកដ្ឋានជំនាញ ដើម្បីរៀបចំផែនការសកម្មភាព និងផែនការថវិកា ឆ្នាំ២០២០ សម្រាប់រៀបចំការបណ្តុះបណ្តាលមុខងារថែទាំផ្លូវជនបទជាលក្ខណៈប្រចាំ និងមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ
- ចូលរួមក្នុងព្រឹត្តិការណ៍រៀនសូត្រថ្នាក់ជាតិ ស្តីពីការគាំទ្រជំនួយបច្ចេកទេសសម្រាប់គម្រោងផ្តល់សេវាអនាម័យជនបទតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ នៅសណ្ឋាគារសាន់វ៉េ
- ចូលរួមក្នុងវេទិកាស្តីពីនីតិកម្ម និងការកែទម្រង់របស់រាជរដ្ឋាភិបាលនៅ សណ្ឋាគារសុខាភ្នំពេញ ។

## IV. ការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការផ្សេងៗ

១. គម្រោងកែលម្អផ្លូវជនបទ ជំហាន ២

អនុវត្តក្នុងខេត្តគោលដៅចំនួន១០ គឺ ខេត្តត្បូងឃ្មុំ កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ គិតត្រឹមដំណាច់ ខែកក្កដានេះ គម្រោងសម្រេចបាន ៖

- ខេត្តត្បូងឃ្មុំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១៩៣,៩ គ.ម សម្រេចបាន ១០០%
- ខេត្តតាកែវ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១០៤,០៨គ.ម សម្រេចបាន ៥៣,៣១%
- ខេត្តកំពង់ស្ពឺ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១៦១,៦០គ.ម សម្រេចបាន ៦៤,២៧%
- ខេត្តកំពង់ឆ្នាំង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៩ខ្សែ មានប្រវែងសរុប ១២៦,៣០គ.ម សម្រេចបាន ៥០,១៤%
- ខេត្តកំពង់ធំ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៤ខ្សែប្រវែង ១១៣,៤០គ.ម សម្រេចបាន ៥៨,៧២%

- ខេត្តសៀមរាប : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៦ខ្សែ មានប្រវែងសរុប ១២៦,២០ គ.ម សម្រេចបាន ៤១,៩៨%
- ខេត្តពោធិ៍សាត់ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ១០ខ្សែ មានប្រវែងសរុប ១២៥,៥០គ.ម សម្រេចបាន ១០០%
- ខេត្តបាត់ដំបង : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៨ខ្សែ មានប្រវែងសរុប ១០១,២០គ.ម សម្រេចបាន ១០០%
- ខេត្តបន្ទាយមានជ័យ :បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៥ខ្សែ មានប្រវែងសរុប ៩០,៧០ គ.ម សម្រេចបាន ១០០%
- ខេត្តកំពង់ចាម : បាន និងកំពុងដំណើរការសាងសង់ផ្លូវក្រាលបេតុងចំនួន ០៦ខ្សែ មានប្រវែងសរុប ៥០គ.ម សម្រេចបាន ១០០% ។

**២. គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំណាក់កាលទី ៦**

គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទដំណាក់កាលទី ៦ ជាគម្រោងសហហិរញ្ញប្បទានឥតសំណងរវាងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តាមរយៈធនាគារ KfW និងរាជរដ្ឋាភិបាលកម្ពុជា អនុវត្តនៅខេត្តបន្ទាយមានជ័យ។ គិតត្រឹមដំណាច់ ខែកក្កដានេះ គម្រោងសម្រេចបាន ៖

- ស្រុកមង្គលបុរី : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០៣ខ្សែ មានប្រវែងសរុប ២៧,២០ គ.ម សម្រេចបាន ៤១,២៧%
- ស្រុកអូរជ្រៅ : បាន និងកំពុងដំណើរការសាងសង់ផ្លូវចំនួន ០១ខ្សែ មានប្រវែងសរុប ២០ គ.ម សម្រេចបាន ៤៥% ។

**៣. គម្រោងសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ**

គម្រោងសាច់ប្រាក់ពលកម្ម សម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករ មានរយៈពេល ០៣ឆ្នាំ គិតចាប់ពី ឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩ និងផ្តោតលើការស្តារ និងកែលំអផ្លូវជនបទ ដោយត្រូវអនុវត្តជា ២ដំណាក់កាល ដែលអនុវត្តក្នុងខេត្តគោលដៅចំនួន ១២ គឺ ខេត្តកណ្តាល តាកែវ ស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ស្ពឺ ព្រៃវែង និងខេត្តឧត្តរមានជ័យ ។ គិតត្រឹមខែសីហានេះ គម្រោងដែលបានស្នើសុំក្រាលគ្រួសក្រហមចំនួន ១៤១គម្រោង បាននិងកំពុងអនុវត្តការងារ បានចំនួន ១៣៦គម្រោង ប្រវែងសរុប ៥៤៥ ១៧៧ម៉ែត្រ ដោយឡែកសម្រាប់ដំណាក់កាល ២ គម្រោង បាននិងកំពុងអនុវត្តចំនួន ១៦០គម្រោង ប្រវែង ១៦១ ៤០៦ម៉ែត្រ ។

**៤. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទទី ២**

- សាងសង់ថ្នាលហាលលាមក សម្រេចបាន ១០០% និងសាងសង់បង្គន់តាមគ្រួសារ (ABC) សម្រេចបាន ០៥% នៅខេត្តបន្ទាយមានជ័យ
- ចុះត្រួតពិនិត្យតាមដានដំណើរការប្រព័ន្ធចែកចាយទឹកខ្នាតតូច នៅខេត្តបន្ទាយមានជ័យ
- សាងសង់បង្គន់តាមគ្រួសារ (ABC) ចំនួន ១៧១ បង្គន់ ជូនប្រជាពលរដ្ឋ បានចំនួន ១២៦ គ្រួសារ និងចាក់កងលូ ជូនប្រជាពលរដ្ឋ បានចំនួន ១០៣ គ្រួសារ នៅខេត្តកំពង់ធំ ។

៥. គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡាងឆាង (Mekong Lancang Cooperation = MLC )

គម្រោងកិច្ចសហប្រតិបត្តិការមេគង្គឡាងឆាងជំហានទី២ សម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទអនុវត្តលើកម្មវិធីចំនួន ២ គឺ៖ ទី១ គម្រោងកាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍសេដ្ឋកិច្ច ជនបទ និងទី២ គម្រោងអភិវឌ្ឍន៍សហគមន៍ចម្រុះតាមដងទន្លេមេគង្គ ដែលជាជំនួយឥតសំណងរបស់សាធារណៈរដ្ឋប្រជាមានិតចិន ។ គម្រោងនេះទើបអនុវត្តក្នុង ខែសីហានេះ ដែលមានលទ្ធផលដូចខាងក្រោម៖

- រៀបចំសិក្ខាសាលា ចំនួន ០៤លើក ស្ដីពីការបន្សាំធន់នឹងការប្រែប្រួលអាកាសធាតុ និងការការពារពីការបំពុលបរិស្ថាន នៅសង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង នៅឃុំពង្រ ស្រុកឆ្លូង ខេត្តក្រចេះ ឃុំពុកឬស្សី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល និងខេត្តព្រៃវែង ដែលមានប្រជាពលរដ្ឋជាប្រធានភូមិ មេឃុំ ក្រុមប្រឹក្សាស្រុកចូលរួមសរុបចំនួន ៣៧៥នាក់ ស្រី ២៨០នាក់ ។
- ចុះសិក្សាពីលទ្ធភាពការសាងសង់ផ្សារជនបទ នៅឃុំព្រៃគ្រី ស្រុកជលគិរី ឃុំផ្សារ ស្រុកបរិបូណ៌ និងឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ចំនួន ០៤លើក
- ចុះសិក្សាពីការរៀបចំ និងបង្កើតសហគមន៍តុ-កៅអី នៅឃុំជើងគ្រាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំនួន ០១លើក
- ចុះសិក្សាប្រមូលទិន្នន័យមូលដ្ឋាន នៅឃុំព្រៃគ្រី ស្រុកជល់គិរី និងឃុំជើងគ្រាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចំនួន ០១លើក ។

## V. សេចក្ដីសន្និដ្ឋាន

យោងតាមសេចក្ដីរាយការណ៍ខាងលើ បានបង្ហាញពីសកម្មភាពជាច្រើនរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដោយបានចុះជាប់ជាប្រចាំនៅតាមគ្រប់ការដ្ឋាន ទាំងការងារសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ទឹកស្អាត អនាម័យ និងការងារបណ្ដុះបណ្ដាលបំណិនជីវិតជូនប្រជាពលរដ្ឋក្នុងការលើកកម្រិតជីវភាពរបស់ប្រជាជននៅតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ។ ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋក៏មានការកើនឡើងជាលំដាប់ ដោយសាររាជរដ្ឋាភិបាលមានគោលនយោបាយ លើកទឹកចិត្តដល់អ្នកវិនិយោគទុនដើម្បីបង្កើតរោងចក្រ បង្កើតការងារជូនអ្នកស្រុក ដែលបានជំរុញឲ្យលក្ខខណ្ឌជីវិតមានការផ្លាស់ប្ដូរកាន់តែប្រសើរឡើងធានាបានគុណភាពនៃជីវិតរបស់ប្រជាជននៅជនបទ ៕

រដ្ឋមន្ត្រី

បណ្ឌិត អ៊ុក រ៉ាប៊ុន